ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

21/7

សាលាដំបូងខេត្តកំពង់ចាម

សាលក្រមរដ្ឋប្បវេណី

លេខៈ ៦១ "ខ" ចុះថ្ងៃទី ០៦

ខែ តុលា ឆ្នាំ ២០១៦

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ចាម

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៦ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១១០ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ដោយមានសមាសភាពៈ

ចៅក្រមជំនុំជម្រះ

លោក [redacted] ជាអនុប្រធានសាលាដំបូងខេត្តកំពង់ចាម

ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដែលមានដើមចោទឈ្មោះ [redacted] ដាវីន ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរមេផ្ទះ ទីលំនៅសព្វ [redacted] ប្តីឈ្មោះ [redacted] សុថៃ មានកូន១នាក់ ឪពុកឈ្មោះ [redacted] សានិត (រ) ម្តាយឈ្មោះ [redacted] សុគន្ធា (រ) ។

និងចុងចម្លើយឈ្មោះ [redacted] សុថៃ អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីយោធា ទីលំនៅសព្វថ្ងៃភូមិ [redacted] ប្រពន្ធឈ្មោះ [redacted] ដាវីន មានកូន១នាក់ ឪពុកឈ្មោះ [redacted] ស្រេង(ស) ម្តាយឈ្មោះ [redacted] សុភាព(រ) ដែលមាន លោកមេធាវី [redacted] ជាតំណាងដោយអាណត្តិៈ ។

អង្គហេតុ និងចំណុចវិវាទៈ

ក/ *ការទាមទាររបស់ដើមចោទៈ*

ដើមចោទប្តឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារៈ

១-ប្តឹងសុំលែងលះពីឈ្មោះ [redacted] សុថៃ

២-សុំចែកទ្រព្យសម្បត្តិរួមៈ ផ្ទះសង់អំពីថ្មទំហំ១១.៥ម X ១៥.៦១ម សង់លើដីទំហំ១៤.៥ម X ៣២ម និងដីលំនៅដ្ឋានមួយកន្លែងទំហំ១៥ម X ៣០.១០ម ស្ថិតនៅភូមិបឹងកុកទី២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម ជា២ចំណែកស្មើគ្នា ។

៣-សុំអំណាចមេបាលើកូន១នាក់ និងសុំអាហារកាតព្វកិច្ចផ្តាច់៥ម៉ឺនដុល្លារអាមេរិក

ខ/ *អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទៈ*

ដើមចោទបានប្តឹងថា ខ្លួនបានរៀបការជាមួយឈ្មោះ [redacted] សុថៃ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ត្រឹមត្រូវតាមច្បាប់ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ទៀតផង ។ ក្រោយពេលរៀបការរួច ខ្លួននិងប្តីបានរស់នៅជាមួយគ្នា នៅផ្ទះដោយឡែក២នាក់ប្តីប្រពន្ធនៅភូមិបឹងកុកទី២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម

Scanned with CamScanner

ពុំដែលមានសេចក្តីសុខទេ ចេះតែមានទំនាស់រកាំរកូសឈ្លោះប្រកែកគ្នា ដោយមូលហេតុឈ្មោះ [redacted] សុថៃ ចេះតែប្រកបមុខរបរទុច្ចរិត ទោះបីជាខ្លួនហាមឃាត់ និងអង្វរយ៉ាងក៏ដោយ ក៏ឈ្មោះ [redacted] សុថៃ នៅតែប្រព្រឹត្តដដែលម្យ៉ាងវិញទៀត បានប្រើអំពើហិង្សាមកលើខ្លួន ជាច្រើនលើកច្រើនសារ និងគិតតែពីផ្គត់ផ្គង់ទៅលើប្រពន្ធដើមព្រមទាំងកូនដើមរបស់គាត់ មិនតែប៉ុណ្ណោះ គាត់បានយកកូនដើមរបស់គាត់១នាក់ មកដាក់បន្ទុកលើខ្លួនឱ្យជួយចិញ្ចឹមបីបាច់ទៀតផង ។ តាំងពីរៀបការមកមានកូន០១នាក់: ឈ្មោះ [redacted] អ៊ីឈុន ភេទស្រី កើតនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០ ទ្រព្យសម្បត្តិរួមមាន: ផ្ទះសង់អំពីថ្មទំហំ១១.៥ម X ១៥.៦១ម សង់លើដីទំហំ១៤.៥ម X ៣២ម និងដីលំនៅដ្ឋានមួយកន្លែង ទំហំ១៥ម X ៣០.១០ម ស្ថិតនៅភូមិបឹងកុកទី២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម ។ នៅពេលនេះខ្លួនអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយឈ្មោះ ជា សុថៃ តទៅទៀតហើយ ។

គ/ *ការអះអាងរបស់ភាគី:*

ដើមចោទ បានអះអាងដូចចំណុចទី១( ការទាមទារដោយដើមចោទ) និងចំណុចទី២( អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទ) ខាងលើ ។ ខ្លួនសុំចែកទ្រព្យសម្បត្តិរួម: ផ្ទះសង់អំពីថ្មទំហំ១១.៥ម X ១៥.៦១ម សង់លើដីទំហំ១៤.៥ម X ៣២ម និងដីលំនៅដ្ឋានមួយកន្លែងទំហំ១៥ម X ៣០.១០ម ស្ថិតនៅភូមិបឹងកុកទី២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម ជា២ចំណែកស្មើគ្នា និងសុំអំណាចមេបាលើកូន០១នាក់ ឈ្មោះ [redacted] អ៊ីឈុន ភេទស្រី កើតនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០ ដោយសុំអាហារកាតព្វកិច្ចផ្តាច់៥ម៉ឺនដុល្លារអាមេរិក។

សាក្សីរបស់ដើមចោទឈ្មោះ លី សានិត បានថ្លែងការណ៍ថា ខ្លួនត្រូវជាឪពុកបង្កើតរបស់ដើមចោទ ។ ខ្លួនពិតជាបាន ផ្តិតមេដៃដឹងឮ នៅលើកិច្ចសន្យាខ្ចីលុយធនាគារអេស៊ីលីដាប្រាកដមែន ។ លុះក្រោយមកឈ្មោះ [redacted] សុថៃ មានបញ្ហា( ជាប់គុក) ប្រធានធនាគារអេស៊ីលីដា សាខាខេត្តកំពង់ចាម បានឱ្យខ្លួនទៅបង់ជំនួសឱ្យឈ្មោះ [redacted] សុថៃ ។ នៅថ្ងៃមួយ មិនចាំថ្ងៃខែ ឈ្មោះ [redacted] សុថៃ បានជេរប្រមាថទៅលើកូនស្រីខ្លួនតាមទូរស័ព្ទ ខ្លួនខឹងពេក ក៏ឈប់ទៅបង់លុយរំលោះឱ្យធនាគារមួយរយៈ ទើបប្រធានធនាគារទូរស័ព្ទឱ្យខ្លួនទៅបង់បន្ត ហើយរហូតដល់ពេលនេះនៅសល់ប្រហែល៥.០០០ដុល្លារទៀត នឹងចប់កាតព្វកិច្ច ហើយនៅពេលខ្ញុំបង់គ្រប់ចំនួន ប្រធានធនាគារថាខ្លួនមានសិទ្ធិដកយកប្លង់ផ្ទះបាន ។ ខ្លួនសូមបញ្ជាក់ថា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ដើមចោទបានទិញដីបន្ទាយផ្នែកខាងក្រោយ ដើម្បីពង្រីកបន្ថែម ដោយខ្ចីលុយខ្លួនចំនួន១៥.០០០ដុល្លារ ។

ចុងចម្លើយឈ្មោះ [redacted] សុថៃ ( អវត្តមាន) ។

ឃ/ *ឯកសារភស្តុតាងដែលដើមចោទជូនមកតុលាការដើម្បីពិនិត្យ:*

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

-សេចក្តីចម្លងសំបុត្រកំណើត

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៣

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៣

-កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៣

Scanned with CamScanner

-កិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣. ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥

-តារាងកាលវិភាគសងប្រាក់ចំនួន០៣សន្លឹក

-តារាងព័ត៌មានសម្រាប់អតិថិជន ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៣

-ប័ណ្ណដាក់ប្រាក់ចំនួន២១សន្លឹក

-លិខិតបញ្ជាក់ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥

-លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥

ង/ *ឯកសារភស្តុតាងដែលមេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយជូនមកតុលាការដើម្បីពិនិត្យ:*

-សេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ របស់ចុងចម្លើយឈ្មោះ [redacted] សុថៃ ថ្លែងចំពោះមុខលោកមេធាវីតំណាងដោយអាណត្តិ ។

-បណ្តឹងមោឃភាពលើឯកសារផ្ទេរសិទ្ធិ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

-លិខិតបញ្ជាក់ទ្រព្យសម្បត្តិរបស់នាងខ្ញុំថៃ បញ្ញាពេជ្រ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦

-លិខិតបញ្ជាក់ទ្រព្យសម្បត្តិរបស់ឪពុកនាងខ្ញុំ [redacted] សុថៃ

ច/ *ចំណុចវិវាទ:* គ្មាន

## សំអាងហេតុ

ឆ្លងតាមកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា:

តុលាការបានធ្វើការកោះហៅគូភាគី ឱ្យចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល នាថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ប៉ុន្តែភាគីចុងចម្លើយ មិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទេ ដោយចុងចម្លើយបានប្រគល់សិទ្ធិឱ្យទៅលោកមេធាវី [redacted] ជាតំណាងដោយអាណត្តិ បន្ទាប់មកតុលាការបានកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ។ ដូច្នេះតុលាការកំណត់ថ្ងៃទាញហេតុផលដោយផ្ទាល់មាត់បាន តាមមាត្រា២០១ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

១/អំពីការសុំលែងលះរបស់ដើមចោទ:

១.១/គូភាគី គឺជាប្តីប្រពន្ធនឹងគ្នា ដែលបានរៀបការតាមច្បាប់ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ ដើម្បីបញ្ជាក់អំពីទំនាក់ទំនងរបស់ខ្លួនតាមផ្លូវច្បាប់ ហើយបានរស់នៅជាមួយគ្នារហូតបានកូន០១នាក់ ។ ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធរបស់គូភាគីក្នុងស្ថានភាពដូចខាងលើនេះ ហៅថា ការរស់នៅមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

១.២/យោងតាមមាត្រា៩៨២ នៃក្រមរដ្ឋប្បវេណី ភាគីអាចដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ឱ្យសម្រេចអំពីការទាមទារសុំលែងលះគ្នាបាន ពីព្រោះគូភាគីបានចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រឹមត្រូវតាមច្បាប់ ។

១.៣/ការទាមទារសុំលែងលះរបស់ដើមចោទ គឺជាការទាមទារមានលក្ខណៈត្រឹមត្រូវ ពីព្រោះដើម

ចោទបានបង្ហាញឆន្ទៈថា ខ្លួនអស់មនោសញ្ចេតនាពីចុងចម្លើយហើយ១ម្យ៉ាងទៀត ចុងចម្លើយបានចុះចោលដើមចោទ ដោយមិនទទួលខុសត្រូវ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។

១.៤/តាមការថ្លែងការណ៍ពីភាគីដើមចោទបញ្ជាក់ថា ខ្លួនប្តឹងសុំឱ្យខ្លួននិងប្តី ទទួលខុសត្រូវលើបំណុលដែលឪពុកខ្លួន បានបង់ទៅធនាគារអេស៊ីលីដាជំនួសពូកខ្លួន ដែលជាប្តីប្រពន្ធកន្លងមក ហើយបានជាឪពុកខ្លួនបង់ជូនធនាគារជំនួស ដោយសារប្តីខ្លួនមានការជាប់ពាក់ព័ន្ធនឹងតុលាការខេត្តបន្ទាយមានជ័យ រហូតដល់សព្វថ្ងៃនេះ ហើយការខ្ចីធនាគារ គឺខ្លួននិងប្តី ជាអ្នកខ្ចីទេ ។ ដូច្នេះ ខ្លួនសំណូមពរដល់ភាគីចុងចម្លើយ ឱ្យទទួលខុសត្រូវបំណុលលើទ្រព្យសម្បត្តិនេះ ។ ដូច្នេះ តុលាការគប្បីទទួលស្គាល់ការទាមទាររបស់ភាគីដើមចោទ ទុកជាការត្រឹមត្រូវតាមច្បាប់ តាមមាត្រា៩១១ នៃក្រមរដ្ឋប្បវេណី។ ភស្តុតាង ដែលមេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ ដាក់ជូនមកតុលាការពិនិត្យ នាកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ គឺជាការអះអាងរបស់សាក្សីឈ្មោះថៃ បញ្ញាជេព្រ ត្រូវជាកូនបង្កើតរបស់ចុងចម្លើយ វាមិនមែនជាសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ ថ្លែងនៅចំពោះមុខមេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយឡើយ ។ ដូចនេះតុលាការមិនគប្បីលើកយកបញ្ហានេះមកពិចារណាឡើយ ។

១.៥/ការថ្លែងការណ៍តបរបស់មេធាវីតំណាងដោយអាណត្តិរបស់ភាគីចុងចម្លើយ ក្នុងការទាមទារគ្រឿងអលង្ការផ្សេង១ ដែលបានបញ្ជាក់ជូនតុលាការនោះ ឃើញថា ការថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិរបស់ភាគីចុងចម្លើយ ពុំមានភស្តុតាងយកមកបញ្ជាក់លើសេចក្តីថ្លែងការណ៍តបរបស់ខ្លួន ឱ្យបានត្រឹមត្រូវតាមច្បាប់នោះទេ ។ ដូច្នេះ តុលាការគប្បីច្រានចោលការប្តឹងទាមទារពីភាគីចុងចម្លើយចោលជាអសារបង់ ។

១.៦/តាមសេចក្តីថ្លែងការណ៍របស់ដើមចោទបញ្ជាក់ថា មូលហេតុដែលខ្លួនប្តឹងសុំលែងលះពីប្តី ដោយសារធ្លាប់ប្រើអំពើហិង្សាមកលើខ្លួន និងជេរប្រមាថទៅលើបុព្វញ្ញាតិខាងខ្លួនទៀតផង ហើយម្យ៉ាងទៀតខ្លួនមិនអាចរួមរស់បន្តទៀតបានឡើយ ដោយសារប្តីខ្លួន បានប្រព្រឹត្តអំពើល្មើសច្បាប់ ដែលសង្គមមិនគាំទ្រ ប៉ុន្តែតាមការអះអាងរបស់ភាគីចុងចម្លើយបញ្ជាក់ថា ខ្លួនពុំព្រមលែងលះពីប្រពន្ធ តែពុំមានភស្តុតាងឱ្យបានច្បាស់លាស់ដើម្បីបញ្ជាក់លើសេចក្តីថ្លែការណ៍តបរបស់ខ្លួនឡើយ ។

១.៧/តាមការថ្លែងការណ៍ពីភាគីដើមចោទបញ្ជាក់ថា ផ្ទះដែលកន្លងមកខ្លួននិងប្តីបានរស់នៅនោះ ពិតជាទ្រព្យរបស់ប្តីខ្លួនមែន តែក្រោយពីខ្លួនបានរៀបការហើយ ផ្ទះនោះធ្វើមិនទាន់ហើយទេ បន្ទាប់មកខ្លួននិងប្តីបានធ្វើបង្ហើយអស់ប្រាក់ប្រហែល៦ម៉ឺនដុល្លារអាមេរិក ហើយក្រៅពីនេះខ្លួនមិនប្តឹងទាមទារអ្វីទេចំពោះផ្ទះនោះ ។ ដូច្នេះ តុលាការយល់ឃើញថា ការថ្លែងការណ៍ពីភាគីដើមចោទ មានលក្ខណៈត្រឹមត្រូវ និងមានការគាំទ្រដោយភស្តុតាងគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីថ្លែងការណ៍ ដូច្នេះទ្រព្យសម្បត្តិ៦ម៉ឺនដុល្លារអាមេរិកជាង ពិតជាទ្រព្យរួម គប្បីចែកជា២ស្មើគ្នា ស្របតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ។

ដូច្នេះ តុលាការគប្បីទទួលស្គាល់ការទាមទាររបស់ភាគីដើមចោទ ទុកជាការត្រឹមត្រូវតាមច្បាប់ ។

២/អំពីការសុំអំណាចមេបាលើកូន( ការកំណត់អ្នកមានអំណាចមេបា)

២.១/គូភាគីមានកូន០១នាក់ឈ្មោះ[redacted] អ៊ីឈុន ភេទស្រី កើតនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០។ ដើមចោទបានសុំអំណាចមេបាលើកូនឈ្មោះ[redacted] អ៊ីឈុន ភេទស្រី ដូច្នេះតុលាការ គប្បីសម្រេចអំពីអ្នកមានអំណាចមេបា

មេបា តាមការទាមទាររបស់ដើមចោទ ។

២.២/តាមសេចក្តីថ្លែងការណ៍របស់ដើមចោទបញ្ជាក់ថា ខ្លួនបានរៀបការជាមួយចុងចម្លើយបានកូនស្រី១នាក់ ហើយភាគីចុងចម្លើយធ្លាប់មានប្រពន្ធមួយព្រមទាំងមានកូនប្រុសស្រីដល់ទៅ៣នាក់ទៀតផង និងម្យ៉ាងទៀតកូនស្រីនេះធ្លាប់រស់នៅជាមួយខ្លួនមានសេចក្តីសុខ និងមានភាពកក់ក្តៅក្នុងចិត្តក្មេងនេះ ហើយស្ថានភាពភាគីចុងចម្លើយសព្វថ្ងៃ កំពុងអនុវត្តទោសនៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ ក្នុងខណៈនោះដើម្បីប្រយោជន៍ និងអនាគតក្មេងនេះ តុលាការគប្បីសម្រេចអំណាចមេបាគ្រប់គ្រងទៅភាគីដើមចោទ ជាអ្នកទទួលខុសត្រូវ ។ ដូច្នេះតុលាការ គប្បីសម្រេចទទួលស្គាល់តាមការទាមទាររបស់ភាគីដើមចោទ ទុកជាត្រឹមត្រូវតាមច្បាប់ តាមមាត្រា ១០៣៧ ចំណុចទី៣ នៃក្រមរដ្ឋប្បវេណី ។

២.៣/ស្ថានភាពរបស់ដើមចោទ មានលក្ខណៈល្អប្រសើរ អាចចិញ្ចឹមបីបាច់ថែរក្សាកូនបាន ដូច្នេះតុលាការសម្រេចតាមការយល់ឃើញខាងលើ ។

៣/អំពីទ្រព្យសម្បត្តិរួមៈ មានផ្ទះសង់អំពីថ្មទំហំ១១.៥ម X ១៥.៦១ម សង់លើដីទំហំ១៤.៥ម X ៣២ម និងដីលំនៅដ្ឋានមួយកន្លែងទំហំ១៥ម X ៣០.១០ម ស្ថិតនៅភូមិបឹងកុកទី២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម . បំណុលជំពាក់គេចំនួន៤៥.០០០ដុល្លារ(ជំពាក់ឪពុកដើមចោទ). បំណុលគេជំពាក់គ្មាន ។ ដីជាប់បន្ទាយទាហាន ជាប់ដីលំនៅដ្ឋានរស់នៅសព្វថ្ងៃ ផ្នែកខាងលិចមួយកន្លែងទំហំ១០១.៥០ម$^2$ ដើមចោទបានទិញក្នុងអំឡុងពេលចុងចម្លើយកំពុងជាប់នៅក្នុងមន្ទីរឃុំឃាំង ក្នុងតម្លៃ១៥.០០០ដុល្លារអាមេរិក ដោយខ្ចីលុយរបស់ឪពុក ។ ដោយឡែកដីលំនៅដ្ឋានមួយកន្លែងទំហំ១៥ម X ៣០.១០ម ស្ថិតនៅភូមិបឹងកុកទី២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម ចុងចម្លើយបានប្រគល់សិទ្ធិឱ្យដើមចោទចាត់ចែងក្នុងការដោះស្រាយជីវភាពគ្រួសារ ប៉ុន្តែលុយដែលបានមកពីការទិញដីនេះ គឺបានមកពីការខ្ចីឪពុកដើមចោទចំនួន៣០.០០០ដុល្លារអាមេរិក ។ តូបលក់ខោខាវលេខ ខ.១៣០ នៅផ្សារធំកំពង់ចាម ជាតូបរបស់ម្តាយដើមចោទ រឺឯឡានកាមរីសេរីឆ្នាំ២០០២ ពណ៌ខ្មៅ០១គ្រឿង ពាក់ផ្លាកលេខ 2Q-2526 ដើមចោទបានលក់យកលុយទៅជូលលោកមេធាវី [redacted] ឱ្យជួយដោះស្រាយរឿងក្តីរបស់ចុងចម្លើយ ដែលកំពុងជាប់នៅក្នុងមន្ទីរឃុំឃាំងខេត្តបន្ទាយមានជ័យ ។

៤/ដើមចោទបានទទួលស្គាល់ថា ផ្ទះនិងដីរស់នៅសព្វថ្ងៃ [redacted] មិនមែនជាទ្រព្យសម្បត្តិរួមក៏ពិតមែន ប៉ុន្តែនៅពេលដើមចោទរៀបការ ផ្ទះនេះទើបតែសាងសង់បានប្រហែល៦០%ទៅ៧០%ប៉ុណ្ណោះ រួចគូភាគីបានរួមគ្នាសាងសង់បន្តរហូតដល់ចប់ជាស្ថាពរ ដោយចំណាយថវិកាអស់ប្រហែល៦ម៉ឺនដុល្លារ ។ ដូចនេះប្រាក់ចំនួន៦ម៉ឺនដុល្លារ គឺជាទ្រព្យសម្បត្តិរួម តុលាការគប្បីសម្រេចតាមច្បាប់ តាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ។ ចំពោះបំណុលរួម គូភាគីបានជំពាក់ប្រាក់ធនាគារអេស៊ីលីដា សាខាខេត្តកំពង់ចាមចំនួន ៣៨.៩៨១ដុល្លារអាមេរិក ហើយបំណុលនេះ គូភាគីបានសងទៅធនាគារអេស៊ីលីដា បានមួយចំនួនក៏មានការអាក់ខាន ដោយចុងចម្លើយជាប់ឃុំខ្លួននៅពន្ធនាគារខេត្តបន្ទាយមានជ័យ ហើយឪពុករបស់ដើមចោទបានបង់ជំនួសបន្តរហូតមក ។

៥/ចំពោះទ្រព្យសម្បត្តិរួមៈ ដីលំនៅដ្ឋានទំហំ១៥ម X ៣០.៥ម ដីជាប់ខាងក្រោយផ្ទះទំហំ១០១.៥០ម$^2$ តាមការថ្លែងការណ៍របស់ដើមចោទបញ្ជាក់ថា ខ្លួនប្តឹងសុំឱ្យបែងចែកតែលើទ្រព្យណាដែលជាទ្រព្យរួមតែប៉ុណ្ណោះ ក្រៅពីនេះខ្លួនគ្មានចិត្តចង់បានលើទ្រព្យអ្នកដទៃទេឡើយ ហើយដោយសារដីខាងលើនេះ ខ្លួននិងភាគីចុង

ចម្លើយ មានបានក្នុងអំឡុងពេលចាប់ដៃគ្នាជាប្តីប្រពន្ធ ហើយការថ្លែងការណ៍របស់ភាគីដើមចោទ មានភស្តុតាងបញ្ជាក់លើសេចក្តីថ្លែងការណ៍បានត្រឹមត្រូវ ។ ដូចនេះតុលាការគប្បីសម្រេចទទួលការទាមទាររបស់ដើមចោទ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៦/លិខិតប្រគល់សិទ្ធិចុះថ្ងៃទី២៥ខែកក្កដា ឆ្នាំ២០១៥ ដែលដើមចោទបានអះអាងថា គឺជាលិខិតដែលចុងចម្លើយបានសរសេរដោយផ្ទាល់ដៃនៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ ហើយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ចុងចម្លើយបែរជាប្តឹងសុំមោឃភាពលើ លិខិតប្រគល់សិទ្ធិចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥ ទៅវិញ នេះបញ្ជាក់ឱ្យឃើញថា ចុងចម្លើយមានភាពក្រឡិចក្រឡុច( មានន័យថា ស៊ីញ៉េនឹងដៃ លប់នឹងជើង) ។

៧/ការប្តឹងទាមទារតបរបស់ភាគីតំណាងដោយអាណត្តិរបស់ចុងចម្លើយ ការថ្លែងការណ៍ពីតំណាងដោយអាណត្តិរបស់ចុងចម្លើយ ពុំមានភស្តុតាង ដើម្បីបញ្ជាក់លើសេចក្តីថ្លែងការណ៍របស់ខ្លួនឱ្យបានត្រឹមត្រូវនោះទេ ដូច្នេះ តុលាការគប្បីសម្រេចច្រានចោលការទាមទារតបពីតំណាងដោយអាណត្តិរបស់ចុងចម្លើយជាអាសារបង់ ។

៨/អាហារកាតព្វកិច្ចផ្តាច់ចំនួន៥០.០០០( ប្រាំម៉ឺន)ដុល្លារអាមេរិក តាមសេចក្តីថ្លែងការណ៍ពីភាគីដើមចោទបញ្ជាក់ថា មូលហេតុដែលខ្លួនប្តឹងសុំឱ្យភាគីចុងចម្លើយ ផ្តល់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនផ្តាច់តែម្តង ដោយសារភាគីចុងចម្លើយ ជាអ្នកមានទ្រព្យសម្បត្តិសមរម្យ និងម្យ៉ាងទៀត ខ្លួនមិនចង់ពាក់ព័ន្ធនឹងភាគីចុងចម្លើយ ឬណាមួយជននេះមានអាកប្បកិរិយាដែលខ្លួនមិនចូលចិត្ត ។

៩/អំពីប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ដើមចោទ ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១/ឱ្យដើមចោទឈ្មោះ [redacted] ដារីន លែងលះពីចុងចម្លើយឈ្មោះ [redacted] សុថៃ ចាប់ពីពេលនេះតទៅ តាមមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ។

/២/ដើមចោទឈ្មោះ [redacted] ដារីន គឺជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] អ៊ីឈុន ភេទស្រី កើតនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០ ដោយមានសិទ្ធិ និងករណីយកិច្ចចិញ្ចឹមបីបាច់ រហូតកូននីតិភាព ។

/ ៣/ទ្រព្យសម្បត្តិរួម:

203.35

-ដីលំនៅដ្ឋានទំហំ១៥ម x ៣០.៥ម .ដីជាប់ខាងក្រោយផ្ទះទំហំ១០១.៥០ម² ស្ថិតនៅភូមិបឹងកុកទី២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម ត្រូវចែកជា២ចំណែកស្មើគ្នា តាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ដោយបង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុថៃ ប្រគល់ប្រាក់ចំនួន៣០.០០០(បីម៉ឺន)ដុល្លារអាមេរិក ទៅឱ្យដើមចោទឈ្មោះ ជួប ដារីន ។

30%

/៤/បង្គាប់ឱ្យគូភាគីទាំងពីរទទួលខុសត្រូវលើបំណុលរួមចំនួន៣៨.៩៨១( បីម៉ឺនប្រាំបីពាន់ប្រាំបួនរយប៉ែតសិបមួយ)ដុល្លារអាមេរិក ។

/៥/បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុថៃ ផ្គត់ផ្គង់អាហារកាតព្វកិច្ចផ្តាច់ចំនួន១០.០០០( មួយម៉ឺន)ដុល្លារអាមេរិក តាមមាត្រ១១៨២ នៃក្រមរដ្ឋប្បវេណី ។ ច្រានចោលការទាមទារលើសពីនេះរបស់ដើមចោទ ។

/៦/ច្រានចោលការទាមទារតបរបស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ ។

៧/ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

កំពង់ធំ, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រម

[redacted]